ឯកសារពិស្តារ

# ឧបករណ៍គណនេយ្យភាពសង្គម

# ការធ្វើផែនការដោយមានការចូលរួម



# ម៉ូឌុល៤: ឧបករណ៍គណនេយ្យភាពសង្គម
# មេរៀន ១:
# ការធ្វើការផែនការដោយមានការចូលរួម

**ខ្លឹមសារមេរៀន** **ទំព័រ**


១.សេចក្ដីផ្ដើម ............ ៣

២.និយមន័យនៃការធ្វើផែនការដោយមានការចូលរួម ............ ៣

៣.គោលបំណងនៃការធ្វើផែនការដោយមានការចូលរួម ............ ៤

៤.គោលការណ៏នៃការធ្វើផែនការដោយមានការចូលរួម ............ ៤

៥.ខួប និងដំណាក់កាលនៃការធ្វើផែនការ ............ ៥

៦.ការធ្វើផែនការដោយមានការចូលរួមនិងគណនេយ្យភាពសង្គម ............ ៨

៧.គន្លឹះសំខាន់ៗនៃមេរៀន ............ ៨

# ការធ្វើផែនការដោយមានការចូលរួម

៙❀៙

## ១. សេចក្តីផ្តើម

ដើម្បីផ្តួចផ្តើមដំណើរការធ្វើផែនការ ការទឹកឃើញដល់ការអភិវឌ្ឍគឺជាគំនិតល្អមួយ ។ អ្នកនឹងនាំទៅរកមធ្យោបាយ ដើម្បីបង្កើតឯកភាពសហគមន៍មួយទៅនឹងអ្វីដែលត្រូវ អភិវឌ្ឍ? ការផ្តួចផ្តើមដំណើរការធ្វើផែនការមានអត្ថន័យ ផ្សេងៗគ្នា សម្រាប់មនុស្សខុសគ្នា។ ប្រជាជនរស់នៅក្នុងភូមិជាមួយគ្នា មានតម្រូវការអភិវឌ្ឍន៍ខុសៗគ្នាដែរដូចជា កុលសម្ព័ន្ធភ្នំនិងជនជាតិដើមភាគតិចអាចចង់បានការការពារព្រៃឈើនិងដីសម្រាប់ការទ្រទ្រង់ផ្នែកចំណីអាហាររយៈពេលយូរអង្វែង ខណៈដែលក្រុមដទៃផ្សេងទៀត គាំទ្រដល់ការបង្កើតអណ្តូងស្នប់ឬសហករណ៏ការងារដើម្បីឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ចភូមិ។ ការរស់នៅរបស់មនុស្សក្នុងគ្រួសារតែមួយក៏មានតម្រូវការខុសគ្នាដែរ។ សម្រាប់បុរសមួយចំនួន ការកសាងផ្លូវគឺជាមធ្យោបាយអភិវឌ្ឍ ព្រោះបង្កើតឱ្យមានឱកាសសេដ្ឋកិច្ច ចំណែកឯស្ត្រីវិញអាចចង់ឱ្យមានប្រភពទឹកនៅជិតៗផ្ទះដើម្បីសន្សំដល់ពេលវេលា រីឯកូនក្មេងអាចចង់បានសាលារៀនដែលមានគុណភាពនៅជិតផ្ទះរបស់ពួកគេ។

អ្នកសម្របសម្រួលធ្វើផែនការបែបចូលរួមត្រូវការបង្កើតបរិយាកាសមួយដែលទស្សនៈរបស់អ្នកគ្រប់គ្នាត្រូវគេទទួលស្គាល់ថាត្រឹមត្រូវ ហើយត្រូវបានបង្ហាញក្នុងការធ្វើផែនការរបស់អ្នកផងដែរ។ រាល់ដំណើរការនៃការប្រជុំ គ្រប់ៗរាល់គ្នាទាមទារការអភិវឌ្ឍមួយតម្រូវឱ្យឆ្លងកាត់ការធ្វើផែនការដែលនឹងបង្កើតឱ្យមានឱកាសសម្រាប់គ្រប់ៗគ្នា។ ករណីនេះអាចកើតឡើងប្រសិន បើអ្នកនាំប្រជាជនឱ្យគិតជាមួយគ្នាលើអ្វីជារូបភាពល្អប្រសើរសម្រាប់ភូមិស្រុករបស់ពួកគេ។ តើពួកគេត្រូវធ្វើអ្វីខ្លះក្នុងកំឡុងពេល ៣ ទៅ ៥ឆ្នាំបន្ទាប់ ដើម្បីឱ្យមានការផ្លាស់ប្តូរនោះ? តើជំនួយរបស់អ្នកណាដែលពួកគេនឹងត្រូវការដើម្បីទទួលបានការផ្លាស់ប្តូរដែលចង់បាន? តើពួកគេនឹងធ្វើការងាររួមគ្នាដោយរបៀបណា ដើម្បីឱ្យសំរេចបានគោលបំណងរួមមួយ?

*(SAS-2 | Module IIB | Session: Participatory Planning | Developing a Micro Plan, 2008)*

## ២. និយមន័យនៃការធ្វើផែនការដោយមានការចូលរួម

ការធ្វើផែនការដោយមានការចូលរួម គឺជាដំណើរការសម្រាប់ឱ្យសហគមន៍ធ្វើការយ៉ាងសកម្មក្នុងការបំពេញតាមគោលដៅ សេដ្ឋកិច្ច-សង្គម ដោយមានការកំណត់បញ្ហា និងគ្រោងការជាសកម្មភាពដោះស្រាយ បញ្ហាទាំងនោះដោយស្មារតីយកចិត្តទុកដាក់។

ជាធម្មតាការធ្វើផែនការដោយមានការចូលរួម ត្រូវការអ្នកជំនាញសម្រាប់ដើរតួជាអ្នកសម្រប សម្រួលនៅក្នុងដំណើការនៃការធ្វើផែនការ។ ការធ្វើផែនការដោយមានការចូលរួមត្រូវមានការចូលរួមពីប្រជា ពលរដ្ឋ ឬ

ក្រុមនៃមនុស្សដែលជាម្ចាស់កម្មសិទ្ធិនេះ ។ ផែនការដែលរៀបចំដោយអ្នកជំនាញការមកពីខាងក្រៅ ទោះជាមានជំនាញបច្ចេកទេសប៉ុណ្ណាក៏ដោយ តែងតែមិនអាចញ៉ាំងឱ្យប្រជាជនចូលរួមក្នុងការអនុវត្តផែនការនោះ យ៉ាងសកម្ម និងពេញចិត្តឡើយ ។ *(Janet Shapiro, Action Planning Toolkit, CIVICUS.)*

## ៣. គោលបំណងនៃការធ្វើផែនការដោយមានការចូលរួម

១. ការកំណត់តម្រូវការរបស់ប្រជាពលរដ្ឋ

២. ធ្វើឱ្យមានការព្រមព្រៀងជាមុន

៣. ពង្រឹងក្រុមដែលមិនបានទទួលបានផលប្រយោជន៍ក្នុងមូលដ្ឋាន

៤. សមាហរណកម្មនៃប្រព័ន្ធចំណេះដឹងក្នុងមូលដ្ឋានទៅក្នុងការរៀបចំគម្រោង

៥. ដំណើរការរៀនពីគ្នាទៅវិញទៅមករវាងគម្រោងនិងប្រជាជនមូលដ្ឋាន

៦. ការគាំទ្រ និងការប្តេជ្ញាចិត្តក្នុងវិស័យនយោបាយ

៧. គណនេយ្យភាពនៅក្នុងអភិបាលកិច្ចមូលដ្ឋាន

*(Kurian Thomas and Ramkumar Bendapudi, Knowledge Managers, Centre for Good Governance)*

## ៤. គោលការណ៍នៃការធ្វើផែនការដោយមានការចូលរួម

១- ការអភិវឌ្ឍគួរតែធ្វើឡើង ដោយការ**ផ្លាស់ប្តូរពីថ្នាក់ក្រោមគឺចេញពីមូលដ្ឋានទៅលើ** ជាជាងពីថ្នាក់លើ មកក្រោម ។

២- ដំណើរការនៃការអភិវឌ្ឍគួរតែត្រូវបានគ្រប់គ្រងលក្ខណៈជា **ការរៀបចំស្ថាប័នតាមបែបធម្មជាតិ** ជា ជាងធ្វើទៅតាមផែនការ គោលដៅ វត្ថុបំណង កម្រិតកំណត់ និងកម្មវិធី ។ គោលដៅនិងកម្រិតកំណត់ អាច ប្រែប្រួល ដូចនេះហើយបានជាពេលវេលាក៏ត្រូវតែ**គិតគូរ ស១និងមានភាពបត់បែនតាមលក្ខខណ្ឌមូលដ្ឋាន** ។

៣- កម្មវិធីអភិវឌ្ឍគួរតែ**តម្រង់ឆ្ពោះទៅរកការពង្រឹងស្ថាប័នមូលដ្ឋាន** មិនមែនផ្តោតតែពីការិយាល័យរដ្ឋ និងរដ្ឋាភិបាលមជ្ឈឹមនោះទេ ។ កម្មវិធីអភិវឌ្ឍគួរតែត្រូវបានជ្រើសរើសតាមលទ្ធភាពរបស់វាដែល អាចបង្កើនសមត្ថភាពគ្រប់គ្រងកិច្ចការអភិវឌ្ឍនៅមូលដ្ឋាន ។ ដោយចាប់ផ្តើមពីសកម្មភាពតូចៗដើម្បីដោះស្រាយបញ្ហាបន្ទាន់ៗនៅមូលដ្ឋាន ដែលតាមរយៈនេះអាចបង្កើនទំនុកចិត្ត ការជឿជាក់ និងបទពិសោធន៍ពីមូលដ្ឋាន ។

៤- ដំណើរការអភិវឌ្ឍន៍ត្រូវបានគាំទ្រដោយស្ថាប័ននៅមូលដ្ឋានជាមួយផ្នែកដទៃទៀតដូចជា ក្រុមសាសនា

យុវជន ក្រុមជួយខ្លួនឯង និងក្រុមដែលចងក្រងនៅមូលដ្ឋានផ្សេងៗ ដែលទាំងអស់នោះមានតួនាទីដឹកនាំលេចធ្លោ។ ការធ្វើឱ្យប្រាកដថាដំណើរការអភិវឌ្ឍន៍ ចាក់ឫស យ៉ាងរឹងមាំនៅស្ថាប័នមូលដ្ឋានជាជាងការដែលស្ថាប័នមូលដ្ឋានគ្រាន់តែក្តាប់បានតែពីចំណុចបច្ចេកទេសជាក់លាក់ រិតតែមានសារសំខាន់ណាស់ទៅទៀត។ ក្នុងដំណើរការអភិវឌ្ឍន៍ បើប្រៀបធៀបទៅ ការរៀបចំ សេវាបច្ចេកទេសពីខាងក្រៅមានភាពងាយស្រួល ឯការចូលរួមប្រឡូកក្នុងសង្គម និងទឹកចិត្តអនុវត្តជាក់ស្តែងគឺត្រូវការពលរដ្ឋនៅមូលដ្ឋាន។ ការមានស្ថាប័នមូលដ្ឋានរឹងមាំពិតជាចាំបាច់ណាស់ ព្រោះថាមូលដ្ឋាននីមួយៗ ទទួលជំនួយគាំទ្រដោយឡែកៗ ឯករាជ្យពីគ្នា ទៅតាមជំនាញបច្ចេកទេស និងបទពិសោធន៍ផ្សេងៗ ដែលមាន។

៥- វាមានលំនាំតាមថ្នាក់ខាងលើ ដែលដំណើរការអភិវឌ្ឍន៍ផ្អែកជាចម្បងលើការជឿជាក់ និងការរៀនសូត្រជាជាងផ្អែកលើជំនាញការ និងការបណ្តុះបណ្តាល។ វាកាន់តែសំខាន់ទៅទៀតសម្រាប់អ្នកដែលនឹងធ្វើសេចក្តីសំរេចចិត្តនៅកម្រិតមូលដ្ឋានត្រូវទទួលទំនុកចិត្តពេញលេញពីប្រជាជនដែលគេតំណាងឱ្យជាជាង ជំនាញការដែលមានការបណ្តុះបណ្តាល។ នេះក៏បានសេចក្តីថា បុគ្គលិក បច្ចេកទេសរបស់ក្រសួង មន្ទីរ នានាគួរតែធ្វើការដោយសាមញ្ញ (ជិះកង់-ធ្វើដូចប្រជាជនធម្មតា) ជាមួយស្ថាប័នមូលដ្ឋាន មិនមែន គ្រាន់តែពិនិត្យវិនិច្ឆ័យស្រួលៗលើផែនការដែលរៀបចំរួចរបស់ ស្ថាប័នមូលដ្ឋានឡើយ ។

*(European Dialogue, 'Promoting Roma Integration at the Local Level. Practical guidance for NGOs and public authorities', 2005.)*

## ៥. ខួប និង ដំណាក់កាលនៃការធ្វើផែនការ

ក្នុងគោលបំណងគ្រប់គ្រង ត្រូវចង់ចាំថា រាល់ផែនការជាទូទៅត្រូវឆ្លង កាត់ខួបនៃដំណាក់កាលសកម្មភាព ។ នេះគេហៅថា ***"ខួបនៃផែនការ"*** ។ ខួបនៃផែនការមាន៤ដំណាក់កាលពាក់ពន្ធ័គ្នា យ៉ាងជិតស្និទ្ធ និងទូលំទូលាយពីមួយទៅមួយ ផ្សេងទៀត :

- ការកំណត់បញ្ហា
- ការរៀបចំកសាងផែនការ
- ការអនុវត្ត និងការត្រួតពិនិត្យតាមដាន
- ការវាយតម្លៃ ។

ពេលធ្វើផែនការ ជំហានដម្បូងគឺត្រូវ**កំណត់បញ្ហា** ហើយក្រោយមកស្វែងរកនូវមធ្យោបាយដោះស្រាយណាដែលល្អជាងគេ ។ នោះគឺត្រូវធ្វើឡើងនៅក្នុងដំណាក់កាលដម្បូងគេ ។

**ក្នុងដំណាក់កាលកសាងផែនការ** អ្នកបង្កើតមាតិការសង្ខេបគម្រោងត្រូវថែងឱ្យច្បាស់លាស់ ពីអ្វីដែលនឹងត្រូវធ្វើ ? សម្រាប់នរណា ? ជាមួយនរណា ?

ហើយត្រូវធ្វើយ៉ាងដូចម្តេច ? ឯកសារដែលកសាងបានត្រឹមត្រូវល្អ ជាលំនាំមួយដើម្បីអនុវត្តនិងបង្កើតទម្រង់បែបបទសម្រាប់ការ វាយតម្លៃ ។

**ក្នុងដំណាក់កាលអនុវត្ត ផែនការ** ត្រូវបានអនុវត្តខណៈដែលធនធានត្រូវបានផ្តល់ឱ្យ សកម្មភាពត្រូវបានអនុវត្ត ហើយនឹងលទ្ធផលត្រូវបានផលិតឡើង ។ តាមរយៈការត្រួតពិនិត្យតាមដានអ្នក ត្រូវដឹងឱ្យប្រាកដថា ការគ្រោងទុកត្រូវអនុវត្តទៅតាមផែនការ ។

**នៅក្នុងដំណាក់កាលវាយតម្លៃ** អ្នកចាំបាច់ត្រូវរកឱ្យឃើញថា តើអ្នកបានសំរេចបំណងនៃផែន ការឬទេ ដូចជាថាតើគម្រោងបានជោគជ័យឬទេ ? តើផែនការអនុវតបានល្អត្រឹមត្រូវឬទេ និងមាន កំហុសខុសឆ្គងត្រង់កន្លែងណា ? ក្នុងដំណាក់កាលនេះ អ្នកត្រូវគូសបញ្ជាក់អំពីមេរៀនដែលបាន សិក្សា ដើម្បីជួយដំណើរការផែនការ និងផែនការទៅអនាគតឱ្យកាន់តែប្រសើរឡើង ។ ប្រសិនបើគ្រប់ ដំណាក់កាលខួបនៃផែនការត្រូវបានអនុវត្តបានល្អត្រឹមត្រូវ ដំណើរការនោះប្រែក្លាយទៅជា វង្វង់ ។




ប្រសិនបើយើងចង់កំណត់ពីដំណើរការនេះឱ្យបានតាមលំដាប់លំដោយ ដូច្នេះយើងអាចកំណត់ពីដំណាក់ កាលសំខាន់ៗក្នុងការបង្កើតគម្រោងខាងក្រោមនេះ :

# ដំណាក់កាលនៃការធ្វើផែនការ

**ការត្រួតពិនិ**

- ❖ នរណាទទួលខុសត្រូវ
- ❖ ធ្វើនៅពេលណា
- ❖ តាមដានសកម្មភាព
- ❖ វាយតម្លៃ
- ❖ ធ្វើដោយរបៀបណា

**ផែនការអនុវ**

- ❖ រៀបរាប់ពីភារកិច្ច
- ❖ នរណាជាអ្នកធ្វើ
- ❖ ធ្វើនៅពេលណា
- ❖ ធ្វើដោយវិធីណា
- ❖ ធនធានដែលត្រូវការ

**គោលដៅ/ទិស**

- ❖ ច្បាស់លាស់/ចំ
- ❖ ដែលអាចវាស់វែងបាន
- ❖ ដែលអាចសំរេចបាន
- ❖ ពិប្រាកដអាចធ្វើបាន
- ❖ កំណត់ពេលវេលា

**ការស្រាវ**

- ❖ ការប្រមូលព័តិមាន
  - -អ្នកភូមិ/បណ្តាញការងារ
  - -អង្គការក្រៅរដ្ឋាភិបាល
  - -រដ្ឋាភិបាល
  - -តម្លៃ
- ❖ វិភាគព័តិមាន

**បញ្ហា**

- ❖ បង្ហាញបញ្ហា
- ❖ រកមូលហេតុ
- ❖ រកដំណោះស្រាយ

*(Participatory Management and Planning, Training Manual, Prepared by Mr. Tan Visal, PACT , PACT Cambodia, 1995)*

## ៦. តើការធ្វើផែនការដោយមានការចូលរួមមានទំនាក់ទំនងនឹងគណនេយ្យភាពសង្គមយ៉ាងដូចម្តេច?

ទាំងការធ្វើផែនការ ទាំងការគ្រោងថវិកាដោយមានចូលរួមរបស់អាជ្ញាធររដ្ឋាភិបាលមូលដ្ឋាន ក្នុងពេលធ្វើផែនការនិងគ្រោងថវិកា បង្កលក្ខណៈឱ្យពលរដ្ឋអាចរួមចំណែកក្នុងដំណើការធ្វើសេចក្តីសម្រេចចិត្តដែលប៉ះពាល់ដល់ជីវភាពរស់នៅនិងវាសនាអនាគតរបស់ខ្លួន។ តាមរយៈការយល់ដឹងពីចំណូលចិត្តរបស់ពលរដ្ឋ ក្នុងការប្រើប្រាស់ធនធានមូលដ្ឋាន នោះរដ្ឋបាលមូលដ្ឋានអាចសម្រេចចិត្តឆ្លើយតបទៅនឹងទំនោរចិត្តរបស់មូលដ្ឋាន។ ការធ្វើផែនការដោយការចូលរួមតែមួយ មិនមែនជាយន្តការគណនេយ្យភាពសង្គមទេ តែវាបង្កលក្ខណៈឱ្យមានគណនេយ្យភាពសង្គម ប្រសិនបើ :

- ពេលចូលរួមជ្រើសអាទិភាព ពលរដ្ឋទទួលបានដំណឹងកាន់តែប្រសើរអំពីការប្តេជ្ញាចិត្តធ្វើការផ្តល់ជូន របស់រដ្ឋាភិបាលមូលដ្ឋាន
- បានចំណាយពេល និងកិច្ចខិតខំប្រឹងប្រែងពិតប្រាកដ នោះពលរដ្ឋនឹងមានទឹកចិត្តខ្ពស់ និងយល់ដឹងពីការប្រើប្រាស់ធនធានរបស់រដ្ឋាភិបាល។ ការធ្វើផែនការ និងគ្រោងថវិកាដោយមានការចូលរួមក្លាយជាយន្តការគណនេយ្យភាពសង្គមប្រសិនបើ :
- ដំណើរការធ្វើផែនការ និងគ្រោងថវិកាបានរួមបញ្ចូលយន្តការជាក់លាក់ដើម្បីអនុញ្ញាតឱ្យពលរដ្ឋអាចតាមដានមើល និងសួរសំណួរពីការអនុវត្តផែនការឆ្នាំកន្លងទៅ ឬក៏គណៈកម្មាធិការពលរដ្ឋដែលចូលរួមក្នុងដំណើរការធ្វើផែនការ និងគ្រោងថវិកាបានបន្តបំពេញមុខងារហើយតាមដានមើលការ អនុវត្តផែនការក្នុងឆ្នាំ។

*(Social Accountability Sourcebook, World Bank Cambodia)*

## ៧. គន្លឹះសំខាន់ៗនៃមេរៀន

អ្នកត្រូវចាំថាការធ្វើផែនការបែបចូលរួម គឺជាដំណើរការផ្តល់អំណាចឱ្យប្រជាជនឱ្យធ្វើជាម្ចាស់លើធនធាន ក្នុងភូមិនិងធ្វើផែនការដើម្បីការលូតលាស់ប្រកបដោយចិរភាព។ ដូច្នេះនៅពេលអ្នកសម្របសម្រួលការធ្វើផែនការបែបចូលរួមអ្នកប្រកាន់គំនិតនេះជាចំណុចស្នូល នោះអ្នកនឹងមិនឃ្លាតចេញឆ្ងាយពីដំណើរការស្នូលនៃការបង្កើតឱ្យមានភាពម្ចាស់ការលើដំណើរការទាំងអស់ និងស៊ីសង្វាក់គ្នានៅក្នុងការងារ ជាពិសេសគឺជម្រុញឱ្យមានអភិបាលកិច្ចល្អ។